# ការវាយតម្លៃកម្រិតហានិភ័យចំពោះជំងឺរបេង សម្រាប់មនុស្សពេញវ័យនៅក្នុងខោនធី Los Angeles

- សូមប្រើប្រាស់បែបបទនេះ ដើម្បីកំណត់**<u>មនុស្សពេញវ័យ</u>**ដែលមិនមានរោគសញ្ញានានា សម្រាប់ការធ្វើតេស្តរកមេរោគរបេង (TB)
- គួរតែមានការធ្វើតេស្តឡើងវិញចំពោះបុគ្គលទាំងឡាយណាដែលបានធ្វើតេស្តទទួលលទ្ធផលអវិជ្ជមានពីពេលកន្លងមក ហើយដែលប្រឈមនឹងកត្តាហានិភ័យ**<u>ថ្មីៗ</u>**ចាប់តាំងពីការវាយតម្លៃចុងក្រោយបង្អស់តែប៉ុណ្ណោះ
- ចំពោះរោគសញ្ញានានានៃជំងឺរបេង ឬការឆ្លុះកាំរស្មី X ទៅលើទ្រូងដែលខុសធម្មតា ហើយដែលស្របទៅនឹងជំងឺរបេងនោះ -> សូមធ្វើការវាយតម្លៃចំពោះជំងឺរបេងដែលសកម្ម

*ការវាយតម្លៃពេញលេញចំពោះជំងឺរបេងដែលសកម្មរួមមាន៖ ការត្រួតពិនិត្យរោគសញ្ញា ការឆ្លុះកាំរស្មី X ហើយប្រសិនបើមានការបញ្ជាក់ រួមមានការធ្វើតេស្តប្រភេទ AFB ទៅលើកំហាក ការធ្វើតេស្តទៅលើមេរោគផ្សេងៗដែលបានបណ្ដុះនៅក្នុងមន្ទីរពិសោធន៍ (cultures) ហើយនិងការធ្វើតេស្តពង្រីកអាស៊ីដនុយក្លេអ៊ិច (nucleic acid amplification) ផងដែរ។ ការធ្វើតេស្តរកជំងឺរបេងដោយការចាក់ម្ជុលទៅក្នុងស្បែក (tuberculin skin test) ដែលទទួលលទ្ធផលអវិជ្ជមាន ឬក៏ការធ្វើតេស្តរកជំងឺរបេងដោយការពិនិត្យឈាម (interferon gamma release assay) ដែលទទួលលទ្ធផលអវិជ្ជមាន មិនអាចសម្រេចថាមិនមានជំងឺរបេងដែលសកម្មនោះទេ។*

សូមគូសធីកនៅក្នុងប្រអប់កត្តាហានិភ័យដែលត្រឹមត្រូវខាងក្រោមនេះ។

មានការណែនាំឱ្យធ្វើតេស្តរកការឆ្លងមេរោគរបេង ប្រសិនបើមានការគូសធីកនៅក្នុងប្រអប់ណាមួយក្នុងចំណោមប្រអប់ទាំង 4 ខាងក្រោមនេះ។

ប្រសិនបើការធ្វើតេស្តរកការឆ្លងមេរោគរបេងទទួលលទ្ធផលវិជ្ជមាន ហើយមានការសម្រេចថាមិនមានជំងឺរបេងដែលសកម្មទេនោះ មានការណែនាំឱ្យទទួលការព្យាបាលការឆ្លងមេរោគរបេង។

☐ **មានកំណើត ឬធ្វើដំណើរទៅ ឬក៏ស្នាក់នៅ**ក្នុងប្រទេសមួយដែលមានអត្រាជំងឺរបេងឡើងខ្ពស់ បានរយៈពេលចំនួនយ៉ាងហោចណាស់ 1 ខែ

- រួមមានទាំងប្រទេសផ្សេងទៀតក្រៅពីសហរដ្ឋអាមេរិក ប្រទេសកាណាដា ប្រទេសអូស្ត្រាលី ប្រទេសណូវែលសេឡង់ ឬប្រទេសទាំងឡាយនៅទ្វីបអឺរ៉ុបប៉ែកខាងលិច និងប៉ែកខាងជើង
- ប្រសិនបើកម្រិតធនធានតម្រូវចាំបាច់ឱ្យមានការផ្ដល់អទិភាពនៅក្នុងក្រុមនេះ សូមផ្ដល់អទិភាពជូនដល់អ្នកជំងឺទាំងឡាយណាដែលប្រឈមនឹងហានិភ័យផ្នែកសុខភាពចំនួនយ៉ាងហោចណាស់មួយយ៉ាង សម្រាប់ការឈានទៅមុខ (សូមមើលតារាងព័ត៌មានការពិត [Fact Sheet] សម្រាប់បញ្ជីហានិភ័យ)
- ពេញចិត្តឱ្យប្រើប្រាស់ការធ្វើតេស្តដោយការពិនិត្យឈាម (Interferon Gamma Release Assay) ជាងការធ្វើតេស្តដោយការចាក់ម្ជុលទៅក្នុងស្បែក (Tuberculin Skin Test) សម្រាប់បុគ្គលទាំងឡាយដែលមិនបានកើតនៅក្នុងសហរដ្ឋអាមេរិក ហើយដែលមានអាយុចាប់ពី 2 ឆ្នាំឡើងទៅ

☐ **ការធ្វើឱ្យភាពស៊ាំចុះខ្សោយ** នាពេលឥឡូវនេះ ឬមានផែនការនឹងធ្វើនៅពេលក្រោយ

- ការឆ្លងមេរោគហ៊ីវ (HIV) ឬអ្នកទទួលផ្លាស់ប្ដូរសរីរាង្គ (គ្រឿងក្នុង) ឬបានទទួលការព្យាបាលដោយប្រើប្រាស់ថ្នាំកាត់បន្ថយការរលាកប្រភេទ TNF-alpha antagonist (ឧ. ប្រភេទ infliximab ឬប្រភេទ etanercept ឬប្រភេទផ្សេងទៀត) ឬការប្រើប្រាស់ថ្នាំប្រភេទស្តេរ៉ូអ៊ីត (steroids) (ស្មើនឹងការប្រើប្រាស់ថ្នាំប្រភេទ prednisone ចំនួនចាប់ពី 15 mg ឡើងទៅក្នុងមួយថ្ងៃ សម្រាប់រយៈពេលចាប់ពី 1 ខែឡើងទៅ) ឬក៏ថ្នាំពេទ្យផ្សេងទៀតណាដែល បង្ក្រាបភាពស៊ាំ

☐ **បានប៉ះពាល់ឬមានទំនាក់ទំនងជិតស្និទ្ធ**ជាមួយនឹងនរណាម្នាក់ដែលអាចចម្លងមេរោគជំងឺរបេងបន្តបាន នៅពេលណាក៏ដោយ

- មជ្ឈមណ្ឌលគ្រប់គ្រង និងទប់ស្កាត់ជំងឺឆ្លង (Centers for Disease Control and Prevention) បង្ហាញថាការវាយតម្លៃទៅលើបុគ្គលដែលមានទំនាក់ទំនង និងការព្យាបាលបុគ្គលមានទំនាក់ទំនងដែលបានឆ្លងមេរោគនោះគឺជាផ្នែកដ៏សំខាន់មួយនៃវិធីសាស្ត្រសម្រា

ប់ការកម្ចាត់ជំងឺរបេងរបស់សហរដ្ឋអាមេរិក

## ☐ប្រវត្តិនៃការមិនមានផ្ទះសម្បែង ឬការជាប់ឃុំឃាំង

- កម្លាំងការងារពិសេសសេវាកម្មបង្ការរបស់សហរដ្ឋអាមេរិក (U.S. Preventive Service Task Force/USPSTF) ណែនាំឱ្យមានការត្រួតពិនិត្យប្រជាជនដែលប្រឈមនឹងហានិភ័យខ្ពស់ជាងមុនក្នុងការឆ្លងជំងឺរបេង ដោយផ្អែកទៅលើកម្រិតហានិភ័យដែលខ្ពស់ជាងមុននៃការប៉ះពាល់ទៅនឹងមេរោគ រួមមានបុគ្គលទាំងឡាយដែលបានរស់នៅទីតាំងដែលមានមនុស្សប្រមូលផ្តុំគ្នាច្រើនកុះករ ហើយដែលប្រឈមនឹងហានិភ័យខ្ពស់ (ឧ. ទីជម្រកសម្រាប់ជនមិនមានផ្ទះសម្បែង និងមណ្ឌលកែប្រែ)

☐មិនមានអ្វីទាំងអស់។ មិនមានបង្ហាញថាមានការធ្វើតេស្តរកជំងឺរបេងទេ នាពេលនេះ។

**អ្នកផ្តល់សេវាកម្មថែទាំសុខភាព៖**____________________

**កាលបរិច្ឆេទនៃការវាយតម្លៃ៖**____________________

**ឈ្មោះអ្នកជំងឺ៖**____________________

**ថ្ងៃខែឆ្នាំកំណើត៖**____________________

*(សូមបិទស្លាកនៅទីនេះ ប្រសិនបើត្រូវការ)*

សូមមើល

**ការណែនាំសម្រាប់អ្នកប្រើប្រាស់ទាក់ទងទៅនឹងការវាយតម្លៃកម្រិតហានិភ័យចំពោះជំងឺរបេងសម្រាប់មនុស្សពេញវ័យនៅក្នុងខោនធី**
Los Angeles (Los Angeles County Adult Tuberculosis Risk Assessment User Guide)

សម្រាប់ព័ត៌មានបន្ថែមអំពីការប្រើប្រាស់បែបបទនេះ។

**បានយកមកប្រើប្រាស់សម្រាប់ខោនធី** LA **ពីឯកសារ ការវាយតម្លៃកម្រិតហានិភ័យចំពោះជំងឺរបេងនៅក្នុងរដ្ឋ** California (California Tuberculosis Risk Assessment) **ដែលអាចរកបាននៅក្នុងទំព័រ** PROVIDERS (**អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព**) **នៅលើគេហទំព័រ** www.ctca.org**។ ដើម្បីធ្វើឱ្យប្រាកដថាអ្នកទទួលបានកំណែប្រែថ្មីបំផុតនោះ សូមចូលទៅកាន់គេហទំព័រ** http://publichealth.lacounty.gov/tb/providertoolkit.htm។

July 2023 (Cambodian)